ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៣៣ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៩-៩-១៩៩៥ –ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៧០ ១៧១៦

១២-៩-១៩៩៥ –ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៧១ ១៧១៧

II. ទីស្តីការគណៈរដ្ឋមន្ត្រី

សេចក្តីសំរេច

០៩-៩-១៩៩៥ –សេចក្តីសំរេចលេខ ៦៥ សសរ ស្តីពីការបំពេញបន្ថែមខ្ទឹមសារក្នុងប្រការ ១ នៃសេចក្តីសំរេចលេខ ១៣៦ សសរ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍ជនបទ ខេត្ត–ក្រុង ១៧១៨

១១-៩-១៩៩៥ –សេចក្តីសំរេចលេខ ៦៦ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៧២០

១៣-៩-១៩៩៥ –សេចក្តីសំរេចលេខ ៦៧ សសរ ស្តីពីការបង្កើតអនុគណៈកម្មការចាត់ចែងការតាំងពិព័រណ៍ នៃរាជរដ្ឋាភិបាល ១៧២១

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១១-៩-១៩៩៥ –ប្រកាសលេខ ២២៤/៩៥ ពម.ប្រក អនុញ្ញាតអោយ «ព្រឹត្តិបត្រ

ពាណិជ្ជកម្ម TRANDING POST» ដំណើរការបោះពុម្ពផ្សាយជាភាសាខ្មែរ និង អង់គ្លេស ១៧២៣
១៣-៩-១៩៩៥ -ប្រកាសលេខ ២២៦ ពម.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការ នៃមន្ទីរពត៌មាន ខេត្តកំពង់ចាម ១៧២៤
១៣-៩-១៩៩៥ -ប្រកាសលេខ ២២៧ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការនៅមន្ទីរពត៌មានខេត្តបាត់ដំបង ១៧២៥
១៣-៩-១៩៩៥ -ប្រកាសលេខ ២២៨/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការនៅមន្ទីរពត៌មាន រាជធានីភ្នំពេញ ១៧២៦
១៤-៩-១៩៩៥ -ប្រកាសលេខ ២៣០/៩៥ ពម.ប្រក ស្តីពីការបង្កើតគណៈកម្មការរៀបចំចងក្រងសៀវភៅផ្នត់ ស្តីពីសមិទ្ធិផល ២ ឆ្នាំ របស់ក្រសួងពត៌មាន ១៧២៧
១៤-៩-១៩៩៥ -ប្រកាសលេខ ២៣១/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង ១៧២៩

២-ឯកសារីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

០៩-៩-១៩៩៥ -ប្រកាសលេខ ១៥៥ ប្រក.វវស.ប ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការរបស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពត ១៧៣០
០៩-៩-១៩៩៥ -ប្រកាសលេខ ១៥៦ ប្រក.វវស.ប ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកណ្តាល ១៧៣១
១៥-៩-១៩៩៥ -ប្រកាសលេខ ១៥៩ ប្រក.វវស.ប ស្តីពីការទទួលស្គាល់លទ្ធផលនៃការប្រឡងសញ្ញាប័ត្រសិល្បៈ និង ស្នាតកប័ត្រសិល្បៈឆ្នាំសិក្សា ១៩៩៤-៩៥ ១៧៣២

៣-ទីស្តីការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

០៥-៩-១៩៩៥ –សេចក្តីប្រកាសលេខ ១០៩ បទ.ប្រក ស្តីពីការគ្រប់គ្រង និង
បែងចែករលកអាកាសវិទ្យុ ១៧៣៨
១៥-៩-១៩៩៥ –សេចក្តីប្រកាសលេខ ១១៨ បទ.ប្រក ស្តីពីការបង្កើតគណៈ
កម្មការអន្តរក្រសួង ១៧៤០

៤-ទីស្តីការ ក្រសួងធម្មការ និង សាសនា

ប្រកាស

១៣-៩-១៩៩៥ –ប្រកាសលេខ ១៨០/៩៥ កធស.ប្រក ស្តីពីការតែងតាំងមន្ត្រី
រាជការ ១៧៤១
១៣-៩-១៩៩៥ –ប្រកាសលេខ ១៨១/៩៥ កធស.ប្រក ស្តីពីការតែងតាំងមន្ត្រី
រាជការ ១៧៤២
១៥-៩-១៩៩៥ –ប្រកាសលេខ ១៨២/៩៥ កធស.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការ
ក្នុងក្របខ័ណ្ឌក្រសួង ១៧៤៣

៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៩-៩-១៩៩៥ –ប្រកាសលេខ ៦៩៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី អែល ដារ៉ា
ជនជាតិខ្មែរ បើកដំណើរការរោងសិប្បកម្មផលិតគ្រឿងសង្ហារឹម ១៧៤៥
០៩-៩-១៩៩៥ –ប្រកាសលេខ ៧០០ ផក.ប្រក អនុញ្ញាតអោយសិប្បកម្មកាត់ដេរ
សំលៀកបំពាក់ ដែលមានអ្នកស្រី ពីង សុខា ជនជាតិខ្មែរ បន្ត

	ដំណើរការផលិតកម្ម	១៧៤៦
១១-៩-១៩៩៥	-ប្រកាសលេខ ៧០១ ផក.ប្រក អនុញ្ញាតអោយលោក ចាន់ លីមហួ ជនជាតិខ្មែរ បន្តដំណើរការរោងសិប្បកម្មផលិតទឹកស៊ីអ៊ីវ ដោយប្តូរយីហោពី «ដួងមាស» មកយីហោ «ផេងលី»	១៧៤៦
១២-៩-១៩៩៥	-ប្រកាសលេខ ៧០២ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន M & V INTERNATIONAL MANUFACTURING LTD តំណាងដោយលោក ឡេ អុងតូម៉ាស់ បង្កើតសាខារោងចក្រកាត់ដេរប៉ាក់សំលៀកបំពាក់សំរាប់នាំចេញ	១៧៤៧
១២-៩-១៩៩៥	-ប្រកាសលេខ ៧០៣ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន WING TAI APPAREL (CAMBODIA) LIMITED តំណាងដោយលោក FRANCIS MAN PIU CHENG សញ្ជាតិ អង់គ្លេស ដំណើរការ ផលិតកម្ម – អាជីវកម្ម រោងចក្រកាត់ដេរសំលៀកបំពាក់ដែលមានឈ្មោះថា «វីងតាយកាត់ដេរសំលៀកបំពាក់ (កម្ពុជា) បំភាត់»	១៧៤៨
១៤-៩-១៩៩៥	-ប្រកាសលេខ ៧០៧ ផក.ប្រក អនុញ្ញាតអោយលោក ប៊ួយ មុំ ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០សេះ	១៧៤៩
១៤-៩-១៩៩៥	-ប្រកាសលេខ ៧០៨ ផក.ប្រក អនុញ្ញាតអោយលោក ស៊ឹម ថុង ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	១៧៤៩
១៤-៩-១៩៩៥	-ប្រកាសលេខ ៧០៩ ផក.ប្រក អនុញ្ញាតអោយលោក អ៊ុង ស៊ីវត្ថា ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៨សេស	១៧៥០
១៤-៩-១៩៩៥	-ប្រកាសលេខ ៧១០ ផក.ប្រក អនុញ្ញាតអោយលោក វេង ឡេង ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតទឹកត្រីពិសេស «មុយ-ហៀង»	១៧៥០
១៤-៩-១៩៩៥	-ប្រកាសលេខ ៧១១ ផក.ប្រក អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានអ្នកស្រី ទឹម ប្រិច ជនជាតិខ្មែរ បើកដំណើរការផលិកម្ម	

ដោយប្រើម៉ាស៊ីន កំលាំង ៨០ សេះ ១៧៥១

៦-អាជ្ញាធរអាកាសចរស៊ីវិល

សេចក្តីប្រកាស

១៤-៩-១៩៩៥ – សេចក្តីប្រកាសលេខ ០៩៥០/៩៥ អអស.ពក ស្តីពីការប្រើប្រាស់ផ្លាករថយន្តថ្មី សំរាប់ចេញ-ចូល អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ១៧៥២

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៧០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងអភិបាលខេត្ត–ក្រុង
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១: លុបឈ្មោះឯកឧត្តម **ខាំ ខៀន** អតីតអភិបាលខេត្តរតនគីរី ដែលបានទទួលមរណភាពកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ចេញពីក្របខ័ណ្ឌរដ្ឋ ។

មាត្រា ២: នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៧១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម ស្តីពីការរៀបចំ និង ការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ ស្តីពីការតែងតាំងមេធាវីនៃរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១: តែងតាំងឯកឧត្តម **កៅ ម៉ុនហុង** ជាមេធាវីនៃរាជរដ្ឋាភិបាល មានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ ។

មាត្រា ២: នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II. ទីស្តីការគណៈរដ្ឋមន្ត្រី

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៦៥ សសរ

ស្តីពីការបំពេញបន្ថែមខ្លឹមសារក្នុងប្រការ ១ នៃសេចក្តីសំរេច

លេខ ១៣៦ សសរ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការ

បង្កើតគណៈកម្មការអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញសេចក្តីសំរេចលេខ ១៣៦ សសរ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សំរេច

ប្រការតែមួយគត់: ប្រការ ១ នៃសេចក្តីសំរេចលេខ ១៣៦ សសរ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ត្រូវបានបំពេញបន្ថែម និង កែសំរួលជាថ្មីឡើងវិញដូចតទៅ :

-អភិបាល ខេត្ត-ក្រុង	ប្រធាន
-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង	អនុប្រធាន
-ប្រធានមន្ទីរផែនការ ខេត្ត-ក្រុង	សមាជិក
-ប្រធានមន្ទីរកសិកម្ម ខេត្ត-ក្រុង	សមាជិក
-ប្រធានមន្ទីរសុខាភិបាល ខេត្ត-ក្រុង	សមាជិក
-ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង	សមាជិក
-ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្ត-ក្រុង	សមាជិក
-ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត-ក្រុង	សមាជិក
-ប្រធានមន្ទីរគ្រប់គ្រងបរិស្ថាន ខេត្ត-ក្រុង	សមាជិក
-ប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត-ក្រុង	សមាជិក
-ប្រធានមន្ទីរកិច្ចការនារី ខេត្ត-ក្រុង	សមាជិក
-ប្រធានអធិការដ្ឋានសង្គមកិច្ចការងារ និងអតីតយុទ្ធជន ខេត្ត-ក្រុង	សមាជិក
-នាយស្នងការនគរបាល ខេត្ត-ក្រុង	សមាជិក
-មេបញ្ជាការយោធា ខេត្ត-ក្រុង	សមាជិក
-គ្រប់អភិបាល ស្រុក-ខណ្ឌ	សមាជិក

-អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង លេខាធិការអចិន្ត្រៃយ៍

-តំណាងអង្គការអន្តរជាតិ និង អង្គការមិនមែនរដ្ឋាភិបាលដែលអនុវត្ត នូវកម្មវិធី/គំរោងការងារអភិវឌ្ឍន៍ជនបទ នៅតាមខេត្ត-ក្រុង សមាជិកសង្កេតការណ៍

ក្នុងករណីដែលសមាជិកណានៃគណៈកម្មការអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង ដូចមានចែងខាងលើមានការកិច្ចមមាញឹកខ្លាំងពេលក្នុងការងារស្នូលរបស់ខ្លួន ឬ មានប្រការណាមួយដែលមិនអាចចូលរួមក្នុងគណៈកម្មការបាននោះ ប្រធានគណៈកម្មការអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង អាចសំរេចក្នុងការផ្ទេរសិទ្ធិ ឬ ជ្រើសរើសសមាជិកថ្មីមកជំនួស តាមការចាំបាច់ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៦៦ សសរ

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្តម **ជា ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការ

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស៊ុំ ម៉ាន់ត** សហរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ជំនួសឯកឧត្តម **ជា ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការ ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅប្រទេសសឹង្ហបុរី ចាប់ពីថ្ងៃទី ០៥ ដល់ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៦៧ សសរ

ស្តីពីការបង្កើតអនុគណៈកម្មការចាត់ចែងការ
តាំងពិព័រណ៍ នៃរាជរដ្ឋាភិបាល

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញសេចក្តីសំរេចលេខ ៦១ សសរ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំតាំងពិព័រណ៍

-តាមសំណូមពរ របស់អគ្គលេខាធិការ នៃរាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានបង្កើតអនុគណៈកម្មការចំនួន ៥ ដើម្បីជួយការងារផ្ទាល់អោយគណៈកម្មការអន្តរក្រសួងរៀបចំតាំងពិព័រណ៍ ស្តីពីសមិទ្ធផលរបស់រាជរដ្ឋាភិបាលដូចខាងក្រោម ÷

១-អនុគណៈកម្មការទទួលបន្ទុកសំរបសំរួលការងារពាក់ព័ន្ធដល់ពិធីការការអញ្ជើញ។ល។ ដែលមានឯកឧត្តម **ម៉ន ឃិន** អនុប្រធានគណៈកម្មាធិការបុណ្យជាតិ បុណ្យអន្តរជាតិ ជាប្រធាន

២-អនុគណៈកម្មការទទួលបន្ទុករៀបចំតុបតែងតាំងពិព័រណ៍ ដែលមានឯកឧត្តម **ខឹម៉េន យ៉េត** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាប្រធាន

៣-អនុគណៈកម្មការទទួលបន្ទុករៀបចំធ្វើសៀវភៅ Brochure ស្តីពីសមិទ្ធផលរបស់រាជរដ្ឋាភិបាលក្នុងរយៈពេល ២ ឆ្នាំ ដែលមានឯកឧត្តម **អ៊ុំ ឆាសៀម** អនុរដ្ឋលេខាធិការក្រសួងពត៌មាន ជាប្រធាន

៤-អនុគណៈកម្មការទទួលបន្ទុកការពារក្នុងពិធីតាំងពិព័រណ៍ ចាប់តាំងពីថ្ងៃបើក រហូតទៅទល់ថ្ងៃបិទ ដែលមានឯកឧត្តម **ហុក ឡុងឌី** អគ្គនាយកនគរបាលក្រសួងមហាផ្ទៃ ជាប្រធាន

៥-អនុគណៈកម្មការទទួលបន្ទុករកថវិកា និង លើកគំរោងចំណូលចំណាយថវិកា ដើម្បីបំរើកិច្ចការតាំងពិព័រណ៍អោយដំណើរការប្រកបដោយជោគជ័យ ដែលមានឯកឧត្តម **លូ ឡាយស្រេង** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាប្រធាន

ប្រការ ២ : អនុគណៈកម្មការនីមួយៗ មានសិទ្ធិជ្រើសតាំងមន្ត្រីមួយចំនួន នៅតាមក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីជួយការងារ ។

ប្រការ ៣ : អនុគណៈកម្មការទាំង ៥ ត្រូវចាប់ដំណើរការតាមភារកិច្ចរៀងៗខ្លួន ដែលបានកំណត់ក្នុងប្រការ ១ ជាបន្ទាន់ ។ ក្នុងករណីជួបការលំបាក ត្រូវរាយការណ៍ជូនប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីសុំដំណោះស្រាយ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

III .ការងារបណ្ដាក្រសួង

១-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២២៤/៩៥ ពម-ប្រក

អនុញ្ញាតអោយ «ព្រឹត្តិប័ត្រពាណិជ្ជកម្ម» ដំណើរការ
បោះពុម្ពផ្សាយជាភាសាខ្មែរ និង អង់គ្លេស

* * *

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រាទី ១៣៩

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញច្បាប់សារពត៌មានដែលរដ្ឋសភា នៃរដ្ឋកម្ពុជា អនុមត័នាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១

– បានឃើញលិខិតស្នើសុំបើក «ព្រឹត្តិប័ត្រពាណិជ្ជកម្ម» របស់លោក **ចិន ប៊ុណ្ណា** ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : អនុញ្ញាតអោយ " ព្រឹត្តិប័ត្រពាណិជ្ជកម្ម " TRADING POST " ដំណើរការបោះពុម្ពផ្សាយជាភាសាខ្មែរ និងអង់គ្លេស ដោយលោក **ចិន មុន្នីណា** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និងស្នើប្រគល់ព្រឹត្តិប័ត្រពាណិជ្ជកម្ម ចំនួន ១៥ ច្បាប់រៀងរាល់លេខចេញផ្សាយ មកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **ចិន មុន្នីណា** ចាងហ្វាងការផ្សាយ «ព្រឹត្តិប័ត្រពាណិជ្ជកម្ម» និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២២៦/៩៥ ពម.ប្រក

ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ

នៃមន្ទីរពត៌មាន ខេត្តកំពង់ចាម

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– យោងចំណារយល់ព្រមលេខ ២២៤៧ អយក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា

-យោងចំណារឯកភាពរបស់ប្រធានមន្ទីរពត៌មានខេត្ត កំពង់ចាម លេខ ១៤៧ ពម ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៥

-ពិនិត្យលើសំណូមពររបស់សាមីជន

សំរេច

ប្រការ ១ : ផ្ទេរលោក **ទ្រាប មុនី** និង ក្របខ័ណ្ឌមួយកន្លែងអោយទៅបំរើការងារនៅក្រោមនិវាទមន្ទីរ អប់រំយុវជន និង កីឡា ខេត្តកំពង់ចាម ។-

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីជនក្នុងប្រការ ១ មន្ទីរពត៌មានខេត្តកំពង់ចាម ត្រូវសំរួលផ្ទេរវិញ្ញាបនប័ត្រផ្តាច់ប្រាក់ទៅអង្គភាពថ្មីដែលសាមីខ្លួនបំពេញ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងពត៌មាន មន្ទីរពត៌មានខេត្តកំពង់ចាម និង សាមីខ្លួនមានភារៈអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២២៧/៩៥ ពម.ប្រក

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

នៅមន្ទីរពត៌មានខេត្តបាត់ដំបង

* * *

-យោងព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

-ពិនិត្យលើសំណើលេខ ៦៤៣ ពមខ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៩៥ របស់មន្ទីរពត៌មានខេត្ត បាត់ដំបង

សំរេច

ប្រការ ១ : លុបឈ្មោះមន្ត្រីរាជការចំនួន ០២នាក់ ចេញពីក្របខ័ណ្ឌមន្ទីរពត៌មានខេត្តបាត់ដំបង នៃក្រសួងពត៌មាន មូលហេតុបោះបង់ចោលការងារដូចមានរាយនាមខាងក្រោមនេះ÷

១-លោក **ទិត ស៊ុខ** ជាបុគ្គលិក បើកបររថយន្ត មន្ទីរពត៌មាន

២-កញ្ញា **ហ៊ី គីមឆោត** ជាបុគ្គលិក ពត៌មានស្រុកបាត់ដំបង

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីជនទាំងពីរ ត្រូវកាត់ផ្តាច់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មន្ទីរពត៌មានខេត្តបាត់ដំបង និង សាមីខ្លួន មានភារៈអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២២៨/៩៥ ពម.ប្រក

ស្តីពីការលុបឈ្មោះមន្ត្រីរាជការនៅ

មន្ទីរពត៌មានរាជធានីភ្នំពេញ

* * *

-យោងព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

-ពិនិត្យលើចំណារបញ្ជូនលេខ ៥៣៧ ពមរ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៥ របស់មន្ទីរពត៌មាន រាជធានីភ្នំពេញ

-ពិនិត្យលើសភាពជាក់ស្តែង

សម្រេច

ប្រការ ១ : លុបឈ្មោះអ្នកស្រី **សុខ នារា** ចេញពីក្របខ័ណ្ឌរបស់ មន្ទីរពត៌មានរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៦ នេះតទៅដោយសាមីខ្លួនបាត់បង់សមត្ថភាពពលកម្ម ហើយ ស្ម័គ្រចិត្តសុំឈប់ ។

ប្រការ ២ : អ្នកស្រី **សុខ នារា** ដូចបានចែងក្នុងប្រការ១ ត្រូវទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងប្រាក់បៀវត្ស អ្នកស្រី **សុខ នារា** :

៣៣.៨០០៛០០ គុណ ៨ : ២៧០.៤០០៛០០

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរពត៌មានរាជធានីភ្នំពេញ និង សាមីខ្លួន មានភារៈអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៣០/៩៥ ពម.ប្រក

ស្តីពីការបង្កើតគណៈកម្មការរៀបចំចងក្រងសៀវភៅ

ផ្តត់ស្តីពីសមិទ្ធផល ២ ឆ្នាំរបស់ក្រសួងពត៌មាន

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញលិខិតលេខ ៥២ ណ.ស.រ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា

– ពិនិត្យលើតម្រូវការ និងភាពចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការ ដើម្បីដឹកនាំក្នុងការរៀបចំចងក្រងសៀវភៅផ្ទត់ ស្តីពីសមិទ្ធផល ២ ឆ្នាំ «ថ្ងៃទី ២ វិច្ឆិកា ឆ្នាំ ១៩៩៣ ដល់ថ្ងៃទី ២ វិច្ឆិកា ឆ្នាំ ១៩៩៥» របស់ក្រសួង ដូចមានសមាសភាព ខាងក្រោមនេះ ÷

–ឯកឧត្តម	**ខៀវ កាញារីទ្ធ**	រដ្ឋលេខាធិការ	ជាប្រធាន
–ឯកឧត្តម	**អ៊ុំ នាស៊ីម**	អនុរដ្ឋលេខាធិការ	ជាអនុប្រធាន
–លោក	**សៀង ឡាប្រេសស្**	នាយកខុទ្ទកាល័យ	ជាសមាជិកអចិន្ត្រៃយ៍
–លោក	**សាន សំម៉ូរី**	អគ្គនាយករង	ជាសមាជិកអចិន្ត្រៃយ៍
–លោក	**សេង ម៉ាលីស**	អគ្គនាយករង	ជាសមាជិកអចិន្ត្រៃយ៍
–លោក	**ឡេង សុជា**	អគ្គនាយករង	ជាសមាជិកអចិន្ត្រៃយ៍
–លោក	**ទី សារ៉ាន់**	អគ្គនាយករង អា.កា.ប៉េ	ជាសមាជិក
–លោក	**ម៉ាន់ សេងលី**	អគ្គនាយករង វិទ្យុ	ជាសមាជិក
–លោក	**ម៉ៅ អាយុទ្ធ**	អគ្គនាយករង ទូរទស្សន៍	ជាសមាជិក
–លោក	**ថាច់ ផែន**	អគ្គនាយករងកាសែតកម្ពុជា	ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច រៀបចំសំរួលបែងចែកទៅតាមបណ្តាជំនាញជាគោល-ការណ៍ធំៗ របស់ក្រសួងដោយចងក្រងជាសៀវភៅផ្ទត់ »

ជាបីភាគ :

ក–សមិទ្ធផលដែលបានសំរេចរួចហើយ «រូបភាព»

ខ–កម្មវិធី ឬគំរោងការងារដែលកំពុងធ្វើ «រូបភាព»

គ–កម្មវិធី និងគំរោងការងារនាពេលអនាគត «រូបភាព»

ប្រការ ៣ : ឯកឧត្តម រដ្ឋលេខាធិការ ឯកឧត្តម អនុរដ្ឋលេខាធិការ អគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានចំណុះក្រសួង ព្រមទាំងសមាជិកក្នុងគណៈកម្មការមានភារៈ អនុវត្តតាមប្រកាស អោយ មានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៣១/៩៥ ពម.ប្រក

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

ចេញពីក្របខ័ណ្ឌក្រសួង

* * *

– បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រមលេខ ០៦ ន.ស ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការអោយប្រើ ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

– បានឃើញអនុក្រឹត្យ ស្តីពីការកែលំអបៀវត្ស កម្មាភិបាល បុគ្គលិក កម្មករ រដ្ឋលេខ ០៥ អ.ន.ក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២

– យោងតាមរបាយការណ៍ ស្តីពីការរាប់មន្ត្រីរាជការ លេខ ០៤១ សល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ អគ្គនាយកដ្ឋានសារពត៌មានខ្មែរ អា.កា.ប៉េ

សំរេច

ប្រការ ១ : លុបឈ្មោះមន្ត្រីរាជការចំនួន ០៦ នាក់ ចេញពីក្របខ័ណ្ឌ អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ អា.កា.ប៉េ នៃក្រសួងពត៌មាន ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ នេះតទៅមានសមាស ភាពដូចខាងក្រោម ÷

១–លោក	**ពយ គីមសួគ៌**	ចូលបំរើការងារ	០១–៧–១៩៨០
២–លោក	**កៅ សាឌុន**	ចូលបំរើការងារ	០៧–៤–១៩៨៤
៣–លោក	**គួល សេងស្រ៊ុន**	ចូលបំរើការងារ	០៧–៤–១៩៨៤
៤–លោក	**កខ សេខ**	ចូលបំរើការងារ	០៧–៤–១៩៨០
៥–លោក	**ឈោ សុវណ្ណ**	ចូលបំរើការងារ	១០–៥–១៩៨៣
៦–លោក	**ស៊ុន ស៊ីថាន**	ចូលបំរើការងារ	១៥–៥–១៩៨៣

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួន ត្រូវបានទទួលម្តងគត់គឺស្មើនឹងប្រាក់បៀវត្ស សរុបប្រចាំខែ គុណនឹងចំនួនឆ្នាំបំរើការងារ មានដូចខាងក្រោមនេះ ÷

១–លោក **ពយ គីមសួគ៌** : ៥០.៥៣០៛ គុណ ១០ = ៥០៥.៣០០៛០០

២-លោក	**កៅ សារុង**	:	៣៣.៨០០៛ គុណ ១០	= ៣៣៨.០០០៛០០
៣-លោក	**គុល សេងស៊ុន**	:	៣៦.៧៩០៛ គុណ ១០	= ៣៦៧.៩០០៛០០
៤-លោក	**កង សេង**	:	៤៣.៦៨០៛ គុណ ១០	= ៤៣៦.៨០០៛០០
៥-លោក	**ហោ សុវណ្ណ**	:	៣៨.២២០៛ គុណ ១០	= ៣៨២.២០០៛០០
៦-លោក	**ស៊ុន ស៊ីថាន**	:	៣៣.៨០០៛ គុណ ១០	= ៣៣៨.០០០៛០០

ប្រការ៣ : អគ្គនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ អា. កា. ប៉េ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

២-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៥ ប្រក.វវស.បុ

ស្ដីពីការផ្លាស់ប្ដូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត

* * *

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើសុំផ្លាស់ លោក **ខៀវ សារិទ្ធ** និង លោក **សៅ ចេន** អនុប្រធានការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុកអង្គរជ័យ នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ

ខេត្តកំពត

–យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួងធម្មការ និងសាសនា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៥

–យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៥

សម្រេច

មាត្រា ១ : មន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពតចំនួន ០២ «ពីរ» នាក់ ដូចមាន រាយនាមខាងក្រោមនេះ ត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារនៅការិយាល័យ ធម្មការ និងសាសនា ស្រុកអង្គរជ័យនៃមន្ទីរធម្មការនិងសាសនា ខេត្តកំពតក្រោម និវាទក្រសួងធម្មការ និងសាសនា ÷

១-លោក **ខៀវ សារិន្ទ** អនុប្រធានការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុកអង្គរជ័យ

២-លោក **សៅ មេន** អនុប្រធានការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុកអង្គរជ័យ

ប្រការ ២ : មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកំពតត្រូវផ្ទេរប្រាក់បៀវត្សរបបឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន និងក្របខ័ណ្ឌពីរកន្លែងជូនមន្ទីរធម្មការនិងសាសនាខេត្តកំពត ។

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពត ព្រម ទាំងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

នុត ណារ៉ាំង

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៦ ប្រក.វវស.ប្

ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរ

វប្បធម៌ និង វិចិត្រសិល្បៈខេត្តកណ្តាល

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

–បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើសុំលុបឈ្មោះលេខ ១៥៤ សន.វវស ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៥ របស់ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល ។

សម្រេច

មាត្រា ១ : លោក **ម៉ុង ខុន** ជាអនុប្រធានការិយាល័យ នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល ត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌមន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៥ ដោយមរណភាព ។

មាត្រា ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និងត្រា

ស៊ីសុវត្ថិ ស៊ីរីរ័ត្ន ម៉ាណារ៉ា

* * *

ភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៥៩ ប្រក.វវស.ប

ស្តីពីការទទួលស្គាល់លទ្ធផលនៃការប្រឡង

សញ្ញាប័ត្រសិល្បៈ និង ស្នាតកប័ត្រសិល្បៈ

ឆ្នាំសិក្សា ១៩៩៤ – ១៩៩៥

* * *

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃកម្ពុជា

-បានឃើញរបាយការណ៍ ស្ដីពីការប្រឡងសញ្ញាប័ត្រសិល្បៈ និងស្នាតកបត្រសិល្បៈ ឆ្នាំសិក្សា ១៩៩៤-១៩៩៥

សម្រេច

ប្រការ ១ : ទទួលស្គាល់ថាបានប្រឡងជាប់សញ្ញាប័ត្រសិល្បៈជាស្ថាពរ នាសម័យប្រឡង ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ សិស្សចំនួន ៧៩ នាក់ ÷

ល.រ	គោត្តនាម និង នាម	លេខតុ	បន្ទប់	ភេទ	ថ្ងៃខែឆ្នាំកំណើត	ឯកទេស	និទ្ទេស
១	កែវ សុផានរ័ត្ន	១	១	ប្រុស	០៨-៧-១៩៧៥	គំនូរបុរាណ	មធ្យម
២	គ្រី លាង	២	១	ប្រុស	១៦-៧-១៩៧៥	គំនូរបុរាណ	មធ្យម
៣	គួយ សុខា	៣	១	ប្រុស	១០-៥-១៩៧៦	គំនូរបុរាណ	មធ្យម
៤	ង៉ែក ទត្តី	៤	១	ប្រុស	២០-១០-១៩៧៤	គំនូរបុរាណ	មធ្យម
៥	ចាន់ សុគន្ធា	៥	១	ប្រុស	០៤-៩-១៩៦៨	គំនូរបុរាណ	មធ្យម
៦	ជ័យ ចាន់ថុល	៦	១	ប្រុស	០៧-៣-១៩៧៦	គំនូរបុរាណ	មធ្យម
៧	ណាក លីហ៊ាង	៧	១	ប្រុស	១២-៣-១៩៧១	គំនូរបុរាណ	មធ្យម
៨	ឈុន សីហា	៨	១	ប្រុស	០៧-៨-១៩៧២	គំនូរបុរាណ	មធ្យម
៩	ឈួន ពន្លក	៩	១	ប្រុស	១១-៤-១៩៧៤	គំនូរបុរាណ	មធ្យម
១០	ញៀម ខេន	១០	១	ប្រុស	១០-៧-១៩៧០	គំនូរបុរាណ	មធ្យម
១១	តូច សេងលុច	១១	១	ប្រុស	១៣-១-១៩៧៣	គំនូរបុរាណ	មធ្យម
១២	ថៃ តារា	១២	១	ប្រុស	១០-៧-១៩៧៦	គំនូរបុរាណ	មធ្យម
១៣	រស់ ប៊ុនរុន	១៣	១	ប្រុស	១៩-៨-១៩៧០	គំនូរបុរាណ	មធ្យម
១៤	វិទូ សារុទ្ធ	១៤	១	ប្រុស	១៧-១២-១៩៧៤	គំនូរបុរាណ	មធ្យម
១៥	រឿង ស៊ីថុល	១៥	១	ប្រុស	១២-៩-១៩៧២	គំនូរបុរាណ	មធ្យម
១៦	លី សុភ្ញាណា	១៦	១	ប្រុស	៣០-១២-១៩៧៥	គំនូរបុរាណ	មធ្យម
១៧	លឹម ទូច	១៧	១	ប្រុស	២៥-៦-១៩៧៤	គំនូរបុរាណ	មធ្យម
១៨	វណ្ណ សុផារិទ្ធ	១៨	១	ប្រុស	០៤-៦-១៩៧៦	គំនូរបុរាណ	មធ្យម
១៩	វ៉ា លេច	១៩	១	ប្រុស	១០-៥-១៩៧៤	គំនូរបុរាណ	មធ្យម
២០	សាន់ ប្រុស	២០	១	ប្រុស	១០-១០-១៩៧៥	គំនូរបុរាណ	មធ្យម
២១	សំ ប៊ូរី	២១	១	ប្រុស	១០-១០-១៩៧៤	គំនូរបុរាណ	មធ្យម
២២	ហេង ក៏	២២	១	ប្រុស	០៦-១០-១៩៧៨	គំនូរបុរាណ	មធ្យម
២៣	ហែម ប៊ុលចន្ថា	២៣	១	ប្រុស	[illegible]	គំនូរបុរាណ	[illegible]
[illegible]	[illegible]	[illegible]	[illegible]	ប្រុស	[illegible]	[illegible]	[illegible]

២៥	ឡុង ស៊ីណាថ	២៥	១	ប្រុស	០៥–២–១៩៧៥	គំនូរបូរាណ	មធ្យម
២៦	អ៊ិន វីណា	២៦	១	ប្រុស	០៤–៨–១៩៧២	គំនូរបូរាណ	មធ្យម
២៧	កាន់ អួន	២៧	២	ប្រុស	១០–១០–១៩៧៧	សៀក	មធ្យម
២៨	កែវ ធីតា	២៨	២	ស្រី	១៥–១០–១៩៨០	របាំបូរាណ	ល្អ
២៩	កែវ បូរ៉ា	២៩	២	ស្រី	២៦–៦–១៩៨០	របាំបូរាណ	មធ្យម
៣០	កែវ វណ្ណកុសល	៣០	២	ប្រុស	០១–១–១៩៧៦	ល្ខោនទិយាយ	មធ្យម
៣១	ទឹម សម្ផស្ស	៣២	២	ស្រី	០៣–៤–១៩៨០	របាំបូរាណ	មធ្យម
៣២	ខុម ផល្លា	៣៣	២	ស្រី	០៥–៥–១៩៧៩	វីយូឡុង	មធ្យម
៣៣	ខៀវ សុធារី	៣៤	២	ស្រី	០១–៨–១៩៧៩	របាំបូរាណ	មធ្យម
៣៤	តឹម សាឯម	៣៥	២	ស្រី	១៣–១–១៩៨១	របាំប្រពៃណី	មធ្យម
៣៥	គៀម ចិន្តា	៣៦	២	ស្រី	០១–១២–១៩៧៨	របាំប្រពៃណី	មធ្យម
៣៦	ឃុត សុថារី	៣៧	២	ស្រី	០៧–៤–១៩៨១	របាំបូរាណ	មធ្យម
៣៧	ចាប សុខុម	៣៨	២	ប្រុស	០៩–៤–១៩៨២	វីយូឡុង	មធ្យម
៣៨	ជ័យ វឌ្ឍនា	៣៩	២	ប្រុស	០៩–១១–១៩៨០	ផ្លុត	ល្អ
៣៩	ជុំ ចន្ទ្រាវុធ	៤០	២	ប្រុស	០១–១១–១៩៨០	វីយូឡុង	មធ្យម
៤០	ជុំ ធីតា	៤១	២	ស្រី	០២–២–១៩៧៧	របាំបូរាណ	មធ្យម
៤១	ឈុន វណ្ណា	៤២	២	ប្រុស	១៦–៥–១៩៧៨	ល្ខោនទិយាយ	មធ្យម
៤២	ផេង ដាណេ	៤៣	២	ស្រី	២២_៥_១៩៧៩	ព្យាណូ	មធ្យម
៤៣	ថោង សុម៉ាលី	៤៤	២	ស្រី	១២_១២_១៩៧៥	ល្ខោនទិយាយ	មធ្យម
៤៤	ទិន ច័ន្ទសំណាង	៤៥	២	ប្រុស	០៩_៩_១៩៨០	វីយូឡុង	មធ្យម
៤៥	គី សុភាព	៤៦	២	ស្រី	១២_៧_១៩៧៧	របាំប្រពៃណី	មធ្យម
៤៦	ទេព លក្ខណា	៤៨	៣	ស្រី	១៦_០១_១៩៧៥	ល្ខោនទិយាយ	មធ្យម
៤៧	ទេព សុភាព	៤៩	៣	ប្រុស	១០_៦_១៩៨០	សៀក	ល្អបង្គួរ
៤៨	ប៊ុន សុធី	៥១	៣	ប្រុស	០២_០១_១៩៧៥	តន្ត្រី	ល្អបង្គួរ
៤៩	ផន សុភ័ក្រ	៥២	៣	ប្រុស	០៦–៨–១៩៨១	វីយូឡុង	ល្អ
៥០	ព្រាប សុគន្ធា	៥៣	៣	ស្រី	០១–០២–១៩៧៩	របាំប្រពៃណី	មធ្យម
៥១	ពេជ្រ តេជៈ	៥៤	៣	ប្រុស	០១–៩–១៩៧៥	ល្ខោនទិយាយ	មធ្យម
៥២	ព្រុំ កុសល	៥៥	៣	ប្រុស	១៥–១–១៩៨១	វីយូឡុង	មធ្យម
៥៣	មាស វណ្ណា	៥៦	៣	ស្រី	១៥–១–១៩៧៩	របាំប្រពៃណី	មធ្យម
៥៤	មាស វិបុល	៥៧	៣	ប្រុស	២០–០២–១៩៧៦	សៀក	មធ្យម
៥៥	មាស សាម៉ុន	៥៨	៣	ស្រី	០១–០១–១៩៧៩	សៀក	ល្អបង្គួរ

៥៦	ម៉េង វិមានតារ៉ា	៦១	៣	ប្រុស	៣១-៩-១៩៨១	វិយូឡុង	មធ្យម
៥៧	ម៉ៅ រ៉ានី	៦២	៣	ប្រុស	០១-៣-១៩៧៦	ល្ខោននិយាយ	មធ្យម
៥៨	យស់ សុភាព	៦៣	៣	ប្រុស	០៥-១០-១៩៧២	សាក់ស្វូ	មធ្យម
៥៩	យឹម សុតារ៉ា	៦៤	៣	ប្រុស	១២-៣-១៩៧៥	ល្ខោននិយាយ	មធ្យម
៦០	វង សុខលីរ៉ាត់	៦៥	៣	ប្រុស	១៩-១០-១៩៨០	ពីយ៉ាណូ	ល្អ
៦១	វិសិទ្ធ សរៈជ័យ	៦៦	៣	ប្រុស	១៨-៧-១៩៨១	វិយូឡុង	មធ្យម
៦២	វុន គន្ធី	៦៧	៤	ស្រី	១២-៦-១៩៧៩	សៀក	ល្អបង្គួរ
៦៣	វុន សុខា	៦៨	៤	ស្រី	១៧-៧-១៩៨០	សៀក	មធ្យម
៦៤	វ៉ែន ភីរម្យ	៦៩	៤	ប្រុស	១៣-២-១៩៧៩	វិយូឡុង	ល្អបង្គួរ
៦៥	សម ប៊ុទី	៧០	៤	ប្រុស	១៨-៧-១៩៧៩	ពីយ៉ាណូ	ល្អបង្គួរ
៦៦	ស៊ិន ច័ន្ទសូនីតា	៧១	៤	ស្រី	១៨-១២-១៩៧៧	របាំប្រពៃណី	មធ្យម
៦៧	ស៊ឹម ទេពវិបុល	៧២	៤	ប្រុស	០៥-១០-១៩៨១	វិយូឡុង	មធ្យម
៦៨	ស៊ឹម សុផារិទ្ធ	៧៣	៤	ស្រី	០៥-១២-១៩៧៩	របាំបុរាណ	មធ្យម
៦៩	សុគន្ធ វិច្ឆនី	៧៤	៤	ស្រី	០៥-៦-១៩៨០	របាំបុរាណ	មធ្យម
៧០	ស៊ូ គីមហួល	៧៥	៤	ស្រី	០២-៥-១៩៨០	សៀក	ល្អ
៧១	សួន ពិសិដ្ឋ	៧៦	៤	ប្រុស	១២-១២-១៩៨០	ពីយ៉ាណូ	មធ្យម
៧២	សែម កំសត់	៧៧	៤	ប្រុស	០៥-០២-១៩៧៩	សៀក	ល្អ
៧៣	សៅ ឈឿន	៧៨	៤	ប្រុស	១៥-០១-១៩៧៩	ល្ខោននិយាយ	មធ្យម
៧៤	ហ៊ួ ចាន់តារា	៧៩	៤	ប្រុស	០៤-៥-១៩៧៨	ល្ខោននិយាយ	មធ្យម
៧៥	ហែម សាម៉េន	៨១	៤	ប្រុស	១៦-៨-១៩៧៦	ល្ខោននិយាយ	មធ្យម
៧៦	ឡាយ សុភាព	៨២	៤	ស្រី	១១-៩-១៩៧៩	នាដឯក	មធ្យម
៧៧	អ៊ុប វុត្ថា	៨៣	៤	ប្រុស	១៦-៩-១៩៨០	នាដឯក	មធ្យម
៧៨	អ៊ុង ឆវីផល្លា	៨៤	៤	ប្រុស	០៧-៩-១៩៧៦	ល្ខោននិយាយ	មធ្យម
៧៩	អ៊ួង សុខា	៨៥	៤	ប្រុស	០១-៨-១៩៧៧	សៀក	មធ្យម

ប្រការ ២ : ទទួលស្គាល់ថាបានប្រឡងជាប់ស្នាតកបត្រសិល្បៈជាស្ថាពរ នាសម័យប្រឡង ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ សិស្សចំនួន ៦២ នាក់ ÷

ល.រ	គោត្តនាម និងនាម	លេខតុ	បន្ទប់	ភេទ	ថ្ងៃខែឆ្នាំកំណើត	ឯកទេស	និទ្ទេស
១	កា ដារ៉ាវុត្ថ	១	១	ប្រុស	១៥-០១-១៩៧៣	គំនូរបុរាណ	មធ្យម
២	គីម តាំង	២	១	ប្រុស	០៧-៦-១៩៧៤	ចំលាក់ប្រាក់	មធ្យម

៣	គួ ហុក	៣	១	ប្រុស	២៩–៣–៧៣	គំនូរផ្សាយ	មធ្យម
៤	ខេន សំណាង	៤	១	ប្រុស	១១–៥–១៩៧៥	ព្យាណូ	មធ្យម
៥	តាម មុំ	៦	១	ប្រុស	១០–៥–១៩៧៥	ចំលាក់ពុម្ព	មធ្យម
៦	តិន មុល	៧	១	ប្រុស	០៩–០១–១៩៧២	វិចិត្រកម្ម	មធ្យម
៧	គីម រិទ្ធី	៨	១	ប្រុស	០៧–១២–១៩៧៤	សាក់ស្វូរ	មធ្យម
៨	ច្រឹក សារឿន	៩	១	ប្រុស	០១–០១–១៩៧៥	របាំប្រពៃណី	មធ្យម
៩	ឆន ច័ន្ទណារុំឡ្យ	១០	១	ប្រុស	១៨–៨–១៩៧៥	គំនូរបុរាណ	មធ្យម
១០	ឆាយ គីមធីរ	១១	១	ប្រុស	០៥–០១–១៩៧២	គំនូរផ្សាយ	មធ្យម
១១	ឆេង ឆៃណា	១២	១	ប្រុស	០៨–០១–១៩៧៦	របាំប្រពៃណី	មធ្យម
១២	ជា មករា	១៣	១	ប្រុស	១៥–០១–១៩៧៣	វិចិត្រកម្ម	មធ្យម
១៣	ជា លក្ខណា	១៤	១	ស្រី	១១–១០–១៩៧៦	របាំ	មធ្យម
១៤	ឈឹម ណាលីន	១៥	១	ស្រី	២៦–០២–១៩៧៦	របាំ	មធ្យម
១៥	ឈុន លាភ	១៦	១	ប្រុស	១០–១០–១៩៧២	ចំលាក់ពុម្ព	មធ្យម
១៦	ឈុន សុជា	១៧	១	ប្រុស	១៥–៨–១៩៧៧	វីយូឡុង	ល្អបង្គួរ
១៧	ញ៉ែម សុខន	១៨	១	ប្រុស	០៥–៤–១៩៧៤	ចំលាក់ឈើ	មធ្យម
១៨	ថារ ចាន់រាសី	១៩	១	ស្រី	២៥–១០–១៩៧៤	ពីយ៉ាណូ	មធ្យម
១៩	ទូច វ៉ាន់នឿន	២០	១	ប្រុស	០២–០១–១៩៧៦	សាក់ស្វូ	មធ្យម
២០	ទូច សល់	២១	១	ប្រុស	០៧–០១–១៩៧៥	ឃឹម	មធ្យម
២១	ទេព ឆក	២២	១	ប្រុស	១៥–៩–១៩៧១	គំនូរផ្សាយ	មធ្យម
២២	ទេព បុណ្ណមី	២៣	២	ប្រុស	១០–១០–១៩៧៣	គំនូរផ្សាយ	មធ្យម
២៣	ន័យ បុរ័ក្រ្ត	២៤	២	ប្រុស	០៣–៦–១៩៧៤	របាំប្រពៃណី	មធ្យម
២៤	នាង ពៅ	២៥	២	ប្រុស	១៦–០១–១៩៧៤	ល្ខោនខោល	មធ្យម
២៥	នូ មនីជោត	២៦	២	ប្រុស	១៩–០២–១៩៧១	វីយូឡុង	ល្អបង្គួរ
២៦	បូ នារី	២៨	២	ស្រី	២៥–៥–១៩៧៧	របាំ	មធ្យម
២៧	ផល ផារិទ្ធ	២៩	២	ប្រុស	២៤–១២–១៩៧៤	ចំលាក់ឈើ	មធ្យម
២៨	ផល សារ៉ាវុធ	៣០	២	ប្រុស	០១–៥–១៩៦៨	យក្ស	មធ្យម
២៩	ព្រាប សារី	៣១	២	ប្រុស	០២–៩–១៩៧១	ល្ខោននិយាយ	មធ្យម
៣០	ពៅ គួ	៣២	២	ប្រុស	០៣–៣–១៩៧៤	ល្ខោនខោល	មធ្យម
៣១	ពុំ សុខន	៣៣	២	ប្រុស	០១–១០–១៩៧៦	ក្លារីណែត	មធ្យម
៣២	ភាវ ចាន់ណារ៉ា	៣៤	២	ប្រុស	០៦–៦–១៩៧៣	គំនូរផ្សាយ	មធ្យម
៣៣	ភី សារី	៣៥	២	ប្រុស	១០–១១–១៩៧០	សាក់ស្វូរ	មធ្យម

៣៤	មាន សំណាង	៣៦	២	ប្រុស	០៥-០១-១៩៧៤	វិចិត្រកម្ម	មធ្យម
៣៥	ម៉ុក សុខុម	៣៨	២	ប្រុស	០៦-៤-១៩៧៥	ល្ខោនខោល	មធ្យម
៣៦	ម៉ុច សម្បត្តិ	៣៩	២	ស្រី	០៥-៦-១៩៧៥	វីយូឡុង	មធ្យម
៣៧	ម៉ៅ គន្ធី	៤០	២	ស្រី	០៤-១២-១៩៧៣	លំអរក្រណាត់	មធ្យម
៣៨	ម៉ៅ ណារិទ្ធ	៤១	២	ប្រុស	០៨-៥-១៩៧៣	របាំប្រពៃណី	មធ្យម
៣៩	ម៉ៅ ធីរ៉ា	៤២	២	ប្រុស	១២-០១-១៩៧០	ចំលាក់ឈើ	មធ្យម
៤០	ម៉ៅ វណ្ណៈ	៤៣	២	ប្រុស	១៣-៦-១៩៧០	វិចិត្រកម្ម	មធ្យម
៤១	មុំ សារ៉ាវង្ស	៤៤	២	ប្រុស	០៨-១១-១៩៧៣	វិចិត្រកម្ម	ល្អបង្គួរ
៤២	យ៉េង យ៉េង	៤៥	៣	ប្រុស	០៨-៥-១៩៧៤	របាំប្រពៃណី	មធ្យម
៤៣	លី ផានណា	៤៦	៣	ស្រី	០១-០១-១៩៧៤	ល្ខោននិយាយ	មធ្យម
៤៤	លី ហួត	៤៧	៣	ប្រុស	២៧-១២-១៩៧០	ចំលាក់ពុម្ព	ល្អបង្គួរ
៤៥	លឹម សេង	៤៨	៣	ប្រុស	០៧-៤-១៩៧២	គំនូរបុរាណ	មធ្យម
៤៦	សុខ ចំរើន	៤៩	៣	ប្រុស	១៣-៦-១៩៧០	ចំលាក់ស្ពាន់	មធ្យម
៤៧	សូត្រ ចាន់ធូ	៥០	៣	ស្រី	២៥-០១-១៩៧៥	ល្ខោននិយាយ	មធ្យម
៤៨	សួន វឌ្ឍា	៥១	៣	ប្រុស	០៤-៤-១៩៧៥	ល្ខោនខោល	មធ្យម
៤៩	សែម សាវុធ	៥២	៣	ប្រុស	១៥-៣-១៩៧៦	វីយូឡុង	មធ្យម
៥០	ស៊ុំ ស៊ីណាន	៥៣	៣	ប្រុស	២១-៦-១៩៧២	វិចិត្រកម្ម	មធ្យម
៥១	សំ វន	៥៤	៣	ប្រុស	០៣-០១-១៩៧៦	ត្រំប៉ែត	ល្អបង្គួរ
៥២	ហង់ វណ្ណទី	៥៥	៣	ប្រុស	០៥-៤-១៩៧៤	ចំលាក់ពុម្ព	មធ្យម
៥៣	ហាស់ សីលា	៥៦	៣	ប្រុស	២២-០១-១៩៧៦	របាំប្រពៃណី	មធ្យម
៥៤	ហុយ ស្រីណា	៥៧	៣	ស្រី	០៣-១២-១៩៧៧	ផ្លូត	ល្អបង្គួរ
៥៥	ហុយ ស្រៀង	៥៨	៣	ប្រុស	២៤-៥-១៩៧៦	ក្លារីណែត	ល្អបង្គួរ
៥៦	ហែម ឆាយា	៥៩	៣	ស្រី	០១-១០-១៩៧៥	ផ្លូត	ល្អ
៥៧	ឡុង អឿន	៦០	៣	ប្រុស	០១-៥-១៩៧៥	ល្ខោននិយាយ	មធ្យម
៥៨	ឡេង នួច	៦១	៣	ប្រុស	២៨-០១-១៩៧១	វិចិត្រកម្ម	មធ្យម
៥៩	អ៊ុក ញ៉ាល់	៦២	៣	ប្រុស	១៦-៤-១៩៧៣	វិចិត្រកម្ម	មធ្យម
៦០	អ៊ុន សុចារី	៦៣	៣	ប្រុស	០៦-៣-១៩៧៥	ចំលាក់ស្មិត	មធ្យម
៦១	អុយ ចាច	៦៤	៣	ស្រី	០៧-៨-១៩៧៦	វីយូឡុង	មធ្យម
៦២	អៀង កញ្ញា	៦៥	៣	ស្រី	១៩-១០-១៩៧៤	វីយូឡុង	ល្អបង្គួរ

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋាន រដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ មានភារកិច្ចអនុវត្តប្រកាសនេះ ។

មាត្រា ៤ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ាង

* * *

៣-ឧិស្តីភារ ក្រសួចប្រៃសណីយ៍ និខ ធូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីប្រកាសរួម លេខ ១០៩ បឧ.ប្រក

ស្តីពីការគ្រប់គ្រង និងបែងចែករលកអាកាសវិទ្យុ

* * *

សូមជំរាបជូន: គ្រប់ក្រសួង និងស្ថាប័ននានា

យោង :–អនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពី ប្រៃសណីយ៍និងទូរគមនា គមន៍ ។

–អនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួង មហាផ្ទៃ ។

ក្នុងគោលបំណងអោយការប្រើប្រាស់រលកអាកាសវិទ្យុប្រកបដោយប្រសិទ្ធភាព និង សុវត្ថិភាពយូរអង្វែង ជៀសវាងការឆ្លងរំខានទៅវិញទៅមក និងដើម្បីអនុវត្តអោយបានត្រឹមត្រូវតាម លំនាំសហភាពទូរគមនាគមន៍អន្តរជាតិ យើងខ្ញុំសូមជំរាបជូននូវភារកិច្ច នៃក្រសួងដែលពាក់ព័ន្ធក្នុង វិស័យនេះ ដូចខាងក្រោម :

១–ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

១.១–គ្រប់គ្រងរលកអាកាសវិទ្យុ និងទទួលខុសត្រូវចំពោះមុខសហភាពទូរគមនាគមន៍អន្តរជាតិ

១.២–ផ្តល់អាជ្ញាប័ណ្ណលើការប្រើប្រាស់រលកអាកាសវិទ្យុសម្រាប់ :

–គ្រប់វិទ្យុទាក់ទងលើកលែងតែរបស់ក្រសួងការពារជាតិនិងក្រសួងមហាផ្ទៃ

–វិទ្យុផ្សាយសម្លេងនិងទូរទស្សន៍ (បន្ទាប់ពីអ្នកសុំបានទទួលសេចក្តីអនុញ្ញាតអោយធ្វើអាជីវកម្មអំពី ក្រសួងពត៌មានហើយ)

១.៣–ធានាសុវត្ថិភាពបច្ចេកទេសជូនអតិថិជនក្នុងការប្រើប្រាស់រលកអាកាសវិទ្យុដោយធ្វើការស្រាវជ្រាវ វាស់ស្ទង់ តាមដាននិងកែតម្រូវ ។

២–ក្រសួងមហាផ្ទៃ :

២.១–សហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុងការធានាសុវត្ថិភាពសង្គមក្នុងការ ប្រើ ប្រាស់វិទ្យុទាក់ទង ។

៣–ក្រសួងពត៌មាន :

៣.១–ផ្តល់ច្បាប់អនុញ្ញាតអោយធ្វើអាជីវកម្មវិទ្យុផ្សាយសំលេង និងទូរទស្សន៍ ។

៣.២–សហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុងការបែងចែកហ្វ្រេកង់ជូនដល់ស្ថានីយ៍ វិទ្យុផ្សាយសម្លេងនិងទូរទស្សន៍ ។

៣.៣–កំរិតកំពស់អង់តែន និង អានុភាពកំលាំងផ្សាយរបស់ស្ថានីយ៍វិទ្យុផ្សាយសម្លេងនិង ទូរទស្សន៍ ។

ក្រសួងនិងស្ថាប័ននានាត្រូវអនុវត្តតាមសេចក្តីប្រកាសរួមនេះគ្រប់កាលៈទេសៈដែលពាក់ព័ន្ធក្នុងការប្រើប្រាស់រលកអាកាសវិទ្យុ ។

សេចក្តីប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រី	រដ្ឋមន្ត្រី	រដ្ឋលេខាធិការ
ក្រសួងមហាផ្ទៃ	ក្រសួងពត៌មាន	ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
ស ខេង- យូ ហុកគ្រី	អៀង មូលី	សូ ឃុន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១៨ បខ.ប្រក

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល

– បានឃើញលិខិតលេខ ១១៥០.សជណ.គប ចុះថ្ងៃទី ២៧–៧–៩៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយដែលមានសមាសភាពដូចតទៅ :

១–ឯកឧត្តម	**ផាន់ គិន**	អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	ប្រធាន
២–ឯកឧត្តម	**កុយ គឹមសិរ**	អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	អនុប្រធាន
៣–ឯកឧត្តម	**ឡាំ ឆួអាន**	អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	អនុប្រធាន
៤–លោក	**កុយ ឡុំ**	នាយកខុទ្ទកាល័យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
៥–លោក	**ញាណ ស្រស់**	ប្រធាននាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញវត្ថុ	សមាជិក
៦–លោក	**ឈុំប សំអាន**	នាយករងខុទ្ទកាល័យ	សមាជិក
៧–លោក	**អាំ សំអាត**	បដិត្ថាហកៈមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តសៀមរាប	សមាជិក
៨–លោក	**ម៉ុក សុផាត**	ប្រធានផ្នែកពិធីការ	សមាជិក
៩–លោក	**ចែម សុទ្ធារ**	មន្ត្រីខុទ្ទកាល័យ	សមាជិក

១០–លោក	សុខ សារ៉េន	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១១–លោក	ជា សុខុម	តំណាងគណៈកម្មការបុណ្យជាតិ–អន្តរជាតិ	សមាជិក
១២–លោក	ចាន់ ធី	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១៣–លោក	ពាជ សារឿន	តំណាងក្រសួងការបរទេស	សមាជិក

ប្រការ ២ : គណៈកម្មការមានភារកិច្ចរៀបចំរោយសម័យប្រជុំអន្តរជាតិ រវាងប្រទេសកម្ពុជា–វៀតណាម–ឡាវ ស្តីពីការអភិវឌ្ឍនវិស័យទូរគមនាគមន៍នៅក្នុងតំបន់ទៅតាមពេលវេលាកំណត់ ។

ប្រការ ៣ : សមាសភាពគណៈកម្មការដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

សុ ឃុន

* * *

៤-ទីស្តីការ ក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៨០-៩៥ កធស. ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

–បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

–បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលចុះថ្ងៃទី ០១–១១– ១៩៩៣

–បានឃើញច្បាប់ ស្តីពីការបង្កើត ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា

-បានឃើញលិខិត ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩៥ របស់នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច

-យោងទៅលើការងារចាំបាច់របស់ក្រសួង និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **គ្រែស សារ៉ុម** បច្ចុប្បន្នប្រធានការិយាល័យរដ្ឋបាល ជាអនុប្រធាននាយកដ្ឋានរដ្ឋបាល ។

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច និង លោក **គ្រែស សារ៉ុម** ត្រូវអនុវត្តតាមសេចក្ដីប្រកាសនេះ ។

ប្រការ ៣ : សេចក្ដីប្រកាសនេះ មានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន ចន្ទរ៉េត្ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៨១-៩១ កធស.ប្រក

ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១-១១-១៩៩៣

-បានឃើញច្បាប់ ស្ដីពីការបង្កើតទីស្ដីការរដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២

-បានឃើញ អនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា

-បានឃើញលិខិតលេខ ៤៦-៩៥ កធស.នធ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៥ របស់នាយកដ្ឋានធម្មការ

សំរេច

ប្រការ ១ : តែងតាំងអ្នកស្រី **ស្រី ស៊ីឈឹម** បច្ចុប្បន្នជាបុគ្គលិក ជាអនុប្រធានការិយាល័យពិធីការ ។

-លោក **មូល និមិត្ត** បច្ចុប្បន្នជាបុគ្គលិក ជាអនុប្រធានការិយាល័យផ្សព្វផ្សាយធម្មទេសនា ។

-លោក **ឈុន ស៊ីយ៉ា** បច្ចុប្បន្នជាបុគ្គលិក ជាអនុប្រធានការិយាល័យអធិករណ៍

-លោក **គីម តារា** បច្ចុប្បន្នជាបុគ្គលិក ជាអនុប្រធានការិយាល័យធម្មការ

ប្រការ ២ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល-ហិរញ្ញកិច្ច នាយកដ្ឋានធម្មការ និង អ្នកស្រី អស់លោក ដែលមានឈ្មោះក្នុងប្រការមួយ ត្រូវអនុវត្តរៀងៗខ្លួន តាមសេចក្ដីប្រកាសនេះ ។

ប្រការ ៤ : សេចក្ដីប្រកាសនេះ មានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន វណ្ណារិត្ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៨២-៩៥ កធស.ប្រក

ស្ដីពីការផ្ទេរមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួង

ធម្មការ និង សាសនា

* * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញ អនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញពាក្យសុំផ្លាស់របស់លោក **ឡៅ ឡុច** ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : លោក **ឡៅ ឡុច** បុគ្គលិកអគ្គាធិការដ្ឋានពុទ្ធិកសិក្សា ត្រូវផ្ទេរអោយទៅធ្វើការនៅមន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់ ។

ប្រការ ២ : បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក **ឡៅ ឡុច** ត្រូវផ្ទេរជូនមន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់ ។

ប្រការ ៣ : មន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់ និង លោក **ឡៅ ឡុច** ត្រូវអនុវត្តតាមប្រកាសនេះរៀងៗខ្លួន ។

ប្រការ ៤ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន វណ្ណារ័ត្ន

* * *

៥-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ: ៦៩៩ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ១:– អនុញ្ញាតអោយអ្នកស្រី **ទឹមឈេ ជារ៉ា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៤៦២៦៩ ភ.ព ចុះថ្ងៃទី ១៨–៣–១៩៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧៨៣ មហាវិថីព្រះមុនី វង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរការរោងសិប្បកម្មផលិតគ្រឿង សង្ហារឹម នៅក្នុងទីតាំងភូមិស្វាយប៉ាក សង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២:– អ្នកស្រី **ទឹមឈេ ជារ៉ា** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ក្នុងរយៈពេល ០៣ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាល កំណត់ប្រកាសនេះ ត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣:– ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សិប្បកម្មត្រូវធានាសុវត្ថិភាពការងារ ធានាបរិដ្ឋានធានា គុណភាពផលិតផលព្រមទាំងត្រូវគោរពរាល់ច្បាប់ និង បទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៤:– សិប្បកម្មនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្ត: ឈើក្រាឡឹងក្ដារកៅ្ស តុ ទូ កៅអី និងបាតស្បែកជើងឈើ ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈ ស្របច្បាប់ដែលសាមីម្ចាស់សិប្បកម្មត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥:– ម្ចាស់សិប្បកម្មត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ អំពីកាលបរិច្ឆេទ នៃការចាប់ផ្ដើមដំណើរការជាផ្លូវការ និង ធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់សិប្បកម្ម ។

ប្រការ៦: – ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់សិប្បកម្មត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៧០០ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ១: – អនុញ្ញាតអោយសិប្បកម្ម កាត់ដេរសំលៀកបំពាក់ ដែលមានអ្នកស្រី **ពិន សុខា** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៧២៦១៧ ភ.ព ចុះថ្ងៃទី ១១–៥–១៩៩០ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៧៥ អឺ០ ផ្លូវព្រះនរោត្តម សង្កាត់បឹងកេងកងទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ២: – ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយ មានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៧០១ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ១: – អនុញ្ញាតអោយលោក **ចាន់ លីមហួ** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩៣១៧៦ ភ.ព ចុះថ្ងៃទី ០៨–៩–១៩៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១១ អឺ០ ផ្លូវ លេខ ១៤៦ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវ ដោយប្តូរឈ្មោះពី «ផ្លូងមាស» មកឈ្មោះ «ផេងលី» វិញនៅក្នុងទីតាំងដីឡូត៍ គ្មានលេខផ្លូវទំនប់ថ្មី ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

ប្រការ២: – លោក **ចាន់ លីមហួរ** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកស៊ីអ៊ីវសញ្ញា «ផ្លូងមាស» ទឹកស៊ីអ៊ីវសញ្ញា «ពែងមាស» ទឹកស៊ីអ៊ីវសញ្ញារូបគោ និងទឹកស៊ីអ៊ីវ

សញ្ញា «រូបគោបី» ស្របតាមគំរូ សញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: – ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ិត ប្រាំង

* * *

ប្រកាសលេខ: ៧០២ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១: – អនុញ្ញាតអោយក្រុមហ៊ុន M & V INTERNATIONAL MANUFACTURING LTD តំណាងដោយលោក **ឡេង តូម៉ាស់** (LEONG TOMAS) ភេទប្រុស អាយុ ៤២ ឆ្នាំ ជនជាតិចិន សញ្ជាតិ ព័រទុយហ្គាល (ម៉ាកាវ) កាន់លិខិតឆ្លងដែន លេខ អ៊ី ០០៣៣៦៩ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៨៨ បង្កើតសាខារោងចក្រកាត់ដេរចាក់សំលៀកបំពាក់សំរាប់នាំចេញមានទីតាំងនៅ អតីតឃ្លាំងរោងចក្រតម្បាញទី ៦ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានមុខសញ្ញាផលិតក្រណាត់ចាក់ ។

ប្រការ ២: – ការបង្កើតរោងចក្រ ត្រូវធ្វើតាមគំរោង ដែលបានចែងក្នុង របាយការណ៍បច្ចេកទេសសេដ្ឋកិច្ច ចុះថ្ងៃទី ២០–១១–១៩៩៤ តំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នឹងត្រូវដំណើរការផលិតកម្មលើទីតាំងដែលបានកំណត់ក្នុងរយៈពេលបួនខែគិតចាប់ពីថ្ងៃដែលបានចុះហត្ថលេខា លើប្រកាសនេះ ។

ប្រការ៣: – សាមីក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្ម–អាជីវកម្មជូនក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៤: – ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវធានាសុវត្ថិភាព ឧស្សាហកម្ម ធានាការពារបរិដ្ឋាន និង ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពច្បាប់ និង បទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៥: –សាមីក្រុមហ៊ុនត្រូវផលិតចេញនូវក្រណាត់ចាក់គ្រប់ប្រភេទដែលមានគំរូ និងផ្លាកសញ្ញាដូចបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៦: – ក្នុងករណីប្រព្រឹត្តល្មើស នឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះនឹងដកហូតវិញដោយគ្មានការតវ៉ាឡើយ ។

* * *

ប្រកាសលេខ: ៧០៣ ឧក.ប្រក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១: – អនុញ្ញាតអោយក្រុមហ៊ុន WING TAI APPAREL (CAMBODIA) LIMITED តំណាងដោយលោក FRANCIS MAN PIU CHENG (ហុងកុង) សញ្ជាតិ អង់គ្លេស កាន់លិខិតឆ្លងដែនលេខ ៥០០០១១៣២៤ ចេញថ្ងៃទី ០៧–១០–១៩៩២ ដំណើរផលិតកម្ម–អាជីវកម្ម រោងចក្រ កាត់ដេរសំលៀកបំពាក់ ដែលមានឈ្មោះថា «វីងតាយកាត់ដេរសំលៀកបំពាក់ (កម្ពុជា)ចំកាត់» មានទីតាំងនៅ # ១៩៨២ ផ្លូវ ជាតិលេខ ៥ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២: – ការបង្កើតរោងចក្រ ត្រូវធ្វើតាមគំរោង ដែលបានចែងក្នុង «INVESTMENT PROPOSAL» ថ្ងៃទី ១២–៨–១៩៩៤ តំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងត្រូវ ដំណើរការផលិតកម្មលើទីតាំងដែលបានកំណត់ក្នុងប្លង់គិតចាប់ពីថ្ងៃបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ៣: – សាមីក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្ម–អាជីវកម្មជូនក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៤: – ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវធានាសុវត្ថិភាព ឧស្សាហកម្ម ធានាការពារបរិដ្ឋាន និង ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពច្បាប់ និង បទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ៥: – សាមីក្រុមហ៊ុនត្រូវផលិតចេញនូវផលិតផល «សំលៀកបំពាក់គ្រប់ប្រភេទ» ដែលមានគំរូ និងផ្លាកសញ្ញាដូចបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៦: – ក្នុងករណីប្រព្រឹត្តល្មើស នឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះ នឹងដកហូតវិញដោយគ្មានការតវ៉ាឡើយ ។

រដ្ឋមន្ត្រីស្តីទី
ហត្ថលេខា និង ត្រា
នូច កានុន

* * *

ប្រកាសលេខ: ៧០៧ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១: – អនុញ្ញាតអោយលោក **មួយ មុំ** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២៥៤១៩ ក.ណ ចុះថៃទី ១០–១២–១៩៨៨ អាស័យដ្ឋានបច្ចុប្បន្នភូមិអញ្ចាញ ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០សេស នៅក្នុងទីតាំង ភូមិហា ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ប្រការ ២: – លោក **មួយ មុំ** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំង ដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៥៦ ភាគរយ ។

ប្រការ៣: – ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៧០៨ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១: – អនុញ្ញាតអោយលោក **ស៊ឹម ថុខ** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៤០៧០១៨ ក.ណ ចុះថ្ងៃទី ២៥–៨–១៩៨៤ អាស័យដ្ឋានបច្ចុប្បន្នភូមិព្រែក អង្កុញ ឃុំសៀមរាម ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីន ផលិតទឹកកកដើម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២.– ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៧០៩ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១:– អនុញ្ញាតអោយលោក **អ៊ុង ស៊ុវត្ថា** ជនជាតិ ខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៣៣២៨ ភ.ព ចុះថ្ងៃទី ២៨–១១–១៩៨៤ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣ ភូមិទី ៥ សង្កាត់លេខ ២ ទីរួមខេត្តស្វាយរៀង ខេត្តស្វាយរៀង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៨សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២:– លោក **អ៊ុង ស៊ុវត្ថា** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៥៦ ភាគរយ ។

ប្រការ៣:– ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៧១០ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១:– អនុញ្ញាតអោយលោក **ទេង ឡេង** ជនជាតិ ខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៤៧៦៦៦ ភ.ព ចុះថ្ងៃទី ១៩–៧–១៩៨៩ អាស័យដ្ឋានបច្ចុប្បន្ន សង្កាត់ ផ្សារដេប៉ូទី ២ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មផលិតទឹកត្រីពិសេស «មុយ–ហៀង» នៅក្នុងទីតាំង ភូមិពោធិមង្គល ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ។

ប្រការ ២:– លោក **ទេព ឡេង** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម–អាជីវកម្ម នូវមុខផលិតផលទឹកត្រីពិសេស សញ្ញាសំគាល់ «រូបសេកពីរ» ស្របតាមគំរូ សញ្ញាសំគាល់ដែលបាន តំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣:– ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មាន គុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៧១១ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រការ ១:–អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានអ្នកស្រី **ទឹម ម្រិច** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០០៥១១៦ ត.ក ចុះថ្ងៃទី ១៦–៩–១៩៨៦ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិថ្នល់បែក សង្កាត់ រកាក្រៅ ទីរួមខេត្តតាកែវ ខេត្តតាកែវ បើកដំណើរការផលិត កម្ម ដោយប្រើម៉ាស៊ីនកំលាំង ៨០ សេស នៅ ក្នុងអាស័យដ្ឋានខាងលើ ។

ប្រការ ២:–អ្នកស្រី **ទឹម ម្រិច** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣:– ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៦-អាជ្ញាធរអាកាសចរស៊ីវិល

សេចក្តីប្រកាស

រាជធានីភ្នំពេញ . ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្តីប្រកាស លេខ : ០៩០៥/៩៥ អ.អ.ស.ព.ក

ស្តីពីការប្រើប្រាស់ផ្លាករថយន្តថ្មីសំរាប់ចេញចូល
អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង

* * *

អាជ្ញាធរអាកាសចរស៊ីវិល

- បានឃើញ អនុក្រឹត្យ លេខ ១១ អនក្រ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ របស់អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា
- ផ្អែកតាមសេចក្តីកំណត់លេខ ០៥២ អ.អ.ស.ព.ក-៩៥ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការប្រើប្រាស់ប័ណ្ណ និង ផ្លាករថយន្តចេញចូលអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ប្រចាំឆ្នាំ ១៩៩៥
- ចំពោះផ្លាករថយន្តថ្មីសំរាប់ចេញចូលអាកាសយានដ្ឋានអន្តរជាតិ ពោធិចិនតុង ប្រចាំឆ្នាំ ១៩៩៥ ដែលទើបបោះពុម្ពហើយ

ប្រកាស

១-ចំពោះផ្លាករថយន្តដែលមានអក្សរ VIP ដែលបានផ្តល់ដោយអាជ្ញាធរអាកាសចរស៊ីវិល សំរាប់ ចេញចូលក្លោងទ្វារ A នៃអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ត្រូវចាត់ទុកជាមោឃៈចាប់ពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

២-ចំពោះផ្លាករថយន្តថ្មី ដែលសំរាប់ចេញចូលអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង មាន ២ ប្រភេទ ÷

ក/-ប្រភេទអក្សរ A សំរាប់ចេញចូលក្លោងទ្វារ A នៃតំបន់ VIP របស់អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ហើយផ្លាករថយន្តនេះ សំរាប់ផ្តល់ជូនមន្ត្រីរាជការអាជ្ញាធរ ក្រសួង មន្ទីរ ស្ថាប័នរដ្ឋ អគ្គរដ្ឋទូត អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនអាកាសចររដ្ឋ និង ឯកជន ស្ថាប័នចាំបាច់មួយចំនួន ដែលមានចំនួនសមស្រប ។

ង/- ប្រភេទអក្សរ S សំរាប់បំរើការងារនៅលើចំណតយន្តហោះក្នុង អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ហើយផ្លាករថយន្តនេះ សំរាប់ផ្តល់ជូនតែអាកាសចរភូមិន្ទ និងក្រុមហ៊ុនអាកាសចរ ដែលមានរថយន្តបំរើសេវាកម្មនៅលើចំណតយន្តហោះ ។

៣--ស្ថាប័នរដ្ឋ ក្រសួង ឯកអគ្គរដ្ឋទូត អង្គការមិនមែនរដ្ឋាភិបាល អាកាសចរភូមិន្ទកម្ពុជា ក្រុមហ៊ុនអាកាសចរឯកជន ក្រុមហ៊ុនវិនិយោគទុននានា ព្រមទាំងស្ថាប័ន ដែលមានបំណងពង់សុំផ្លាករថយន្តថ្មី សំរាប់ចេញ–ចូលអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ត្រូវមាន លិខិតស្នើសុំជាផ្លូវការដោយមានឈ្មោះអ្នកប្រើ និង លេខរថយន្តភ្ជាប់ជាមួយ ។

៤–នាយកដ្ឋានរដ្ឋបាល អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង និង ស្ថាប័នមានការពាក់ព័ន្ធត្រូវអនុវត្ត តាមសេចក្តីប្រកាសនេះ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ម៉ុក សំឯល

* * *

បោះពុម្ពនៅរោងពុម្ពធិស្តិការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៦៥៨ រៀល